# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ : ០៤៩/០៤ ក.អ.ជ ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤

## ប្រកាស

## ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោង និងតែងតាំងនាយកគំរោង និងអ្នកគ្រប់គ្រងគំរោងសំរាប់បំរើការងារនៅអង្គភាពគ្រប់គ្រងគំរោង ក្នុងក្របខ័ណ្ឌឥណទាននៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៃគំរោងផ្គត់ផ្គង់ទឹកជនបទ និងអនាម័យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ/អជប ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកភារកិច្ច និង ការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- អនុស្សរណៈយោគយល់គ្នារវាង ADB's Mission ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២
- យោងតាមតំរូវការចាំបាច់

**សម្រេច**

ប្រការ១: បង្កើតឡើងនូវអង្គភាពគ្រប់គ្រងគំរោង (PMU) សំរាប់អនុវត្តគំរោងឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានទីស្នាក់ការនៅ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ២: តែងតាំងនាយកគំរោង (Project Director) និង អ្នកគ្រប់គ្រងគំរោង (Project Manager) សំរាប់អនុវត្តគំរោងផ្គត់ផ្គង់ទឹកជនបទ និងអនាម័យ ក្នុងខេត្តកំពង់ធំ ខេត្តកំពត និងខេត្តពោធិសាត់ ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាពដូចខាងក្រោម:

១- លោក **ម៉ៅ សារ៉ាយ** នាយកគំរោង

២- លោក **នួន ពេជ្រនិមិត្ត** អ្នកគ្រប់គ្រងគំរោង

ប្រការ៣: មន្ត្រីដូចមានចែងក្នុងប្រការ ២ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណ ទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដូចមានចែងក្នុងឯកសារគំរោង ។

ប្រការ៤: អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ និង សាមីជនដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី**
**ជា សាភឹន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ កំពត និង ពោធិសាត់
- ធនាគារអភិវឌ្ឍន៍អាស៊ី ADB

<u>ដើម្បីជូនជ្រាប:</u>

- ដូចមានចែងក្នុងប្រការ ៤

<u>ដើម្បីអនុវត្ត:</u>

- ឯកសារ-កាលប្បវត្តិ